**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

# រវាង

# ក្រុមហ៊ុនឌូហ៊ីស្ត (ខេមបូឌា) ខូអ៊ិលធីឌី

# និង

# តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋាន

# នៃក្រុមហ៊ុនឌូហ៊ីស្ត (ខេមបូឌា) ខូអ៊ិលធីឌី

## ស្តីអំពីការបើកប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១០ ព្រឹក នៅក្នុងរោងចក្រ ឌូហ៊ីស្ត (ខេមបូឌា) មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត សហជីពមូលដ្ឋាន ដែលមានភាពជាតំណាងបំផុតប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅតែកង្វះខាតវត្ថុធាតុដើម និងការរីករាលដុះដាលនៃមេរោគកូរ៉ូណា ដែលជាកត្តាចម្បងដែលធ្វើឲ្យទីផ្សារនៅអឺរ៉ុប អាមេរិក កាណាដាក៏ដូចជាទីផ្សារពិភពលោកមានការធ្លាក់ចុះ និងមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ អ្នកបញ្ជាទិញបានផ្អាក និងបញ្ឈប់ការបញ្ជាទិញ និងមិនអនុញ្ញាតិឲ្យមានការនាំទំនិញចេញផងដែរ។

ទាំងនេះជាមូលហេតុដែលនាំឲ្យក្រុមហ៊ុនឌូហ៊ីស្ត (ខេមបូឌា) ខូអ៊ិលធីឌី ពុំមានលទ្ធភាពក្នុងការផ្តល់ការងារជូនកម្មករនិយោជិតមួយចំនួនក្នុងមួយរយៈពេលនេះ។

ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារ របស់កម្មករនិយោជិត ចំនួន......៥៧៤.......(ស្រី......៤២១...... នាក់) ជាលើកទី៥ ដែលមានរយៈពេលគឺចាប់ពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២០ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតនឹងទទួលបានប្រាក់ឧបត្ថម្ភតាមសេចក្តីណែនាំលេខ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ដែលនឹងត្រូវបានផ្តល់ជូនតាមរយៈប្រព័ន្ធធនាគារដែលបាននឹងកំពុងអនុវត្ត។

យើងខ្ញុំទាំងអស់គ្នាយល់ព្រមក្នុងការបើកប្រាក់ឈ្នួលប្រចាំខែមួយខែម្តងជំនួសឲ្យការបើកប្រាក់ឈ្នួលពីរដងក្នុងមួយខែក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។

អង្គប្រជុំបានចប់វេលាម៉ោង១០ និង ៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសង្ខាង មានភាពស្និទ្ធស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និងសហការគ្នាយ៉ាងល្អៗ

ថ្ងៃព្រហស្បតិ៍ ៣ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២០

**តំណាងកម្មករនិយោជិត និងតំណាងសហជីព** **នាយកក្រុមហ៊ុន**

| | | | | |
|---|---|---|---|---|
| ឃ្លោក កាន់ដាក | ខាត់ ប៊ុនណា | ផៃ ស្រា | | |
| ស៊ុយ កុមារពេជ្រ | ណែម សោភ័ណ្ឌ | ត្រាំ ថារី | | |
| សំ សាម៉ុល | អន បូរិន | ស៊ាត ណារ៉ែន | ចាប រិទ្ធ | |
| ហៃ គីស៊ា | រ័ត្ន សំណាង | ខុន សុខហេង | ហង់ សុគា | សារឿន ណារី |
| ពៅ ពិសី | សេង ឌន | សុខ គឹមហេង | គ្រី សៀកឡាង | រុងរឿង វិច្ឆនីន |
| ឃន វ៉ាន់ថេត | ឈឺន សុភ័ក្រ | ឈិន សុបិន្តថន | ម៉ាន់ វ៉ាម៉ូ | ម៉េង ហួរ |

Dewhirst (Cambodia) Co., Ltd.

Mr. Ian McBeth